

# ការចិញ្ចឹមមាន់

# សេចក្តីផ្តើម

មាន់ គឺជាសត្វមួយប្រភេទដែលប្រជាជនយើងធ្លាប់ចិញ្ចឹមតាំងពីយូរយារណាស់មកហើយ

- ការចិញ្ចឹមមាន់បានចូលរួមចំណែកក្នុងការរក្សាសន្តិសុខស្បៀងអាហារ
- ការរីកចំរើនសេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិរួមចំណែកក្នុងការ កាត់បន្ថយភាពក្រីក្រក្នុងជួរប្រជាជន ។
- អាចធានាបាននូវស្ថិរភាពសង្គម និងភាពរុងរឿងរបស់ប្រទេសជាតិនាអនាគត
- ការចិញ្ចឹមមាន់មិនមែនជាការលំបាកទេ បើសិនជាយើងយកចិត្តទុកដាក់ក្នុងការចិញ្ចឹមបានល្អត្រឹមត្រូវតាមបច្ចេកទេស ។

**ការចិញ្ចឹមមាន់ចំណាយថវិការយ៉ាងតិចបំផុត នោះហើយអាចរួមចំណែក ៖**

- កាត់បន្ថយនូវការកង្វះខាតស្បៀងអាហារ
- ចូលរួមក្នុងវិស័យយេនឌ័រ ដែលជាពិសេសខាងស្ត្រីនឹងអាចមានលទ្ធភាពរកចំណូលក្នុងគ្រួសារបានយ៉ាងល្អ និង មិនបាច់ទៅឆ្ងាយពីផ្ទះសំបែង ។
- កាត់បន្ថយការធ្វើចំណាកស្រុក
- កាត់បន្ថយការប្រើអំពើហឹង្សាក្នុងគ្រួសារ និងមានតុល្យភាពសិទ្ធិរវាងស្ត្រី និងបុរស ។
- ប្រើប្រាស់ឱ្យអស់លទ្ធភាពធនធានដែលមាននៅក្នុងតំបន់ជាចំណីមាន់

## សារៈសំខាន់នៃការចិញ្ចឹមមាន់

ការចិញ្ចឹមមាន់អាចផ្តល់នូវអត្ថប្រយោជន៍មួយចំនួនដូចជា៖

- ផ្តល់ស៊ុត និង សាច់ធ្វើម្ហូបអាហារដ៏មានឱជារសសំរាប់រាងកាយ
- ផ្តល់រោម និងស្លាបសំរាប់ធ្វើឧបករណ៍ប្រើប្រាស់ផ្សេងៗ
- ផ្តល់លាមកសំរាប់ធ្វើជីមានគុណភាពល្អសំរាប់ដំណាំផ្សេងៗ អាចយកទៅប្រើជាចំណីត្រី និងបំប៉នដល់គោជំទង់ៗ ។
- ជួយដោះស្រាយបញ្ហាបានមួយចំនួនពេលជួបប្រទះការខ្វះខាតចំពោះមុខ ។
- ផ្តល់ផលប្រយោជន៍ឆាប់រហ័ស ប្រើរយៈពេលខ្លី ធ្វើឱ្យសេដ្ឋកិច្ចគ្រួសារបានធូរធារមួយកំរិត ។


ម្ហូបអាហារ
ថវិកា
ជីកំប៉ុស្តិ៍ និងជីស្រស់
ស៊ុតមាន់
មេមាន់
កូនមាន់

ការស្វែងយល់ទីផ្សារ

មុនចាប់ផ្តើមចិញ្ចឹមមាន់អ្នកត្រូវដឹង

- តើគេចូលចិត្តមាន់ប្រភេទណា គួរលក់មាន់នៅកន្លែងណា គួរលក់មាន់នៅពេលណា

ដើម្បីចិញ្ចឹមមាន់ឆាប់លូតលាស់ និងឆាប់ទទួលផល យើងត្រូវដឹងពីកត្តាសំខាន់ៗ ស្តីពីបច្ចេកទេសក្នុងការចិញ្ចឹមមានដូចខាងក្រោមៈ

១- អំពីជំរករបស់មាន់

២- អំពីពូជ និង ការជ្រើសរើសពូជ

៣- អំពីចំណីអាហារ និង ទឹក

៤- អំពីការថែទាំ និង វិធានការការពារជំងឺ

១-អំពីជំរក

១.១-ទីតាំងសាងសង់ជំរក

-ត្រូវសង់លើដីទួល មិនលិចទឹក

-ឆ្ងាយពីដើមឈើធំៗ

-ត្រូវសង់ក្នុងទិសខាងកើតខាងលិច (បណ្តោយស្រប និងដំណើរព្រះអាទិត្យ)

-ត្រូវសង់ឱ្យឆ្ងាយពីផ្ទះបន្ទិច

-ឆ្ងាយពីសំលេងអ៊ូអរ និង ប្រភពទឹក

-ត្រូវមានខ្យល់ និង ពន្លឺចេញចូលល្អគ្រប់គ្រាន់




(ADP/RPRP)-2005




គំរូទ្រុងមាន់ សំរាប់ក្រុម LIG (ADP/ RPRP)

រៀបរៀង និងគូរដោយវិស្វករបសុពេទ្យ ឌាំ ទិលិដ្ឋ

2005









# ១.២-ការរៀបចំសំភារៈសំរាប់មាន់

## គំរូស្នូកទឹក និងចំណីមាន់



# សកម្មភាពផលិតប្រដាប់ដាក់ទឹកជូនកសិករ





អំពីទំហំទ្រុងសមស្រប

ទំហំទ្រុងសមស្រប សំរាប់ការចិញ្ចឹមមាន់មាន៖

- មួយម៉ែត្រការ៉េ សំរាប់មាន់ បីក្បាល
- ពីរម៉ែត្រការ៉េ សំរាប់មាន់ពី ៦-៧ក្បាល
- អង្រុតធំមួយសំរាប់មេ និង កូន (មាន់មួយសំបុក)
- ទំហំជំរកមាន់ ៣ម គុណ ៤ម គុណ ២ម សំរាប់មាន់ ពី ៣០-៤០ក្បាល

# សំភារៈសំរាប់ធ្វើសំបុកមាន់



## ២-អំពីពូជ និងការជ្រើសរើសពូជ

### ២.១-អំពីពូជ

### ២.១.១-ពូជមាន់ក្នុងស្រុក

ពូជមាន់ក្នុងស្រុកមាន ពូជមាន់ថៃ មាន់សំឡី មាន់សំពៅ មាន់ស្គួយ មាន់ក្រញាស់ មាន់កណ្តូង មាន់ខ្មៅ មាន់គក មាន់ប្រជល់ ។

**គុណសម្បត្តិល្អរបស់មាន់ស្រុក:**

- អាចចិញ្ចឹមលែងដោយពុំចាំបាច់ខាតបង់ពេលវេលាថែរក្សាច្រើន
- មានលក្ខណៈបន្សាំល្អជាមួយអាកាសធាតុ និងជំងឺមួយចំនួន
- អាចរកស៊ីចំណីអាហារដោយខ្លួនឯង

-អាចក្រាបពង និងចិញ្ចឹមកូនរបស់វាដោយខ្លួនឯង

-អាចការពារកូន ពីសត្រូវមកយាយីបានមួយចំនួនទៀត

-អាចផ្តល់ស៊ុតបាន ៣-៤ដងក្នុង១ឆ្នាំ

-សាច់ណែនមានរសជាតិឆ្ងាញ់ ខ្លាញ់តិច

-ងាយរកទីផ្សារ លក់បានតំលៃថ្លៃទាំងញី និងឈ្មោល

-ចំណាយដើមទុនអស់តិច ក្នុងការចិញ្ចឹម

# ពូជមាន់សំពៅ





# ពូជមាន់កណ្ដូង





# ពូជមាន់ស្គួយ (កូនមាន់)



## ២.១.២-ពូជមាន់បរទេស

ពូជមាន់នាំចូលកន្លងមកនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងគេចែកចេញជា ៣ប្រភេទគឺ

-ពូជមាន់ផ្តល់សាច់

-ពូជមាន់ផ្តល់ស៊ុត

-ពូជមាន់ផ្តល់ស៊ុតផង និងសាច់ផង

ពូជមាន់ទាំងនោះមាន ពូជមាន់ឡឺហ្គន អ៊ីសាប្រោន ពីលមុត ហាបបាដ ប្រ៉េរល័រ

**គុណសម្បត្តិមាន់ពូជនាំចូល**

-លូតលាស់រហ័ស ចិញ្ចឹមតែ ៤៥ថ្ងៃបានលក់ (ចំពោះមាន់ពូជផ្តល់សាច់)

-ផ្តល់ស៊ុតច្រើន (ចំពោះមាន់ផ្តល់ស៊ុត)

**គុណវិបត្តិ**

-មិនសូវធន់នឹងជំងឺ(ងាយឈឺ) ហើយពិបាកបន្សាំទៅនឹងអាកាសធាតុក្នុងស្រុក

-មិនចេះរកចំណី មិនចេះចិញ្ចឹមកូន និងថែរក្សាកូន

-មិនអាចចិញ្ចឹមលែងបាន ទាមទារមានទ្រុង និងបច្ចេកទេសត្រឹមត្រូវ

-ត្រូវការផ្តល់ចំណី និងទឹកគ្រប់គ្រាន់ ប្រកបដោយគុណភាព

-ត្រូវមានការថែទាំ និងវិធានការអនាម័យ និងការការពារត្រឹមត្រូវ

## ២.១.៣-ពូជមានកូនកាត់

-ការចិញ្ចឹមមាន់គឺដើម្បីរកកំរៃដោះស្រាយជីវភាពគ្រួសារ

-ដូច្នេះយើងត្រូវតែធ្វើការបង្កាត់ពូជមាន់របស់យើង ដើម្បីឱ្យវាឆាប់ធំ និងផ្តល់ស៊ុតច្រើន

-ត្រូវធ្វើការជ្រើសរើសពូជមាន់ក្នុងស្រុកដែលល្អ យកទៅបង្កាត់ជាមួយពូជមាន់នាំចូល ដែលផ្តល់សាច់ច្រើន

- យើងត្រូវបង្កាត់រវាងមាន់ពូជក្នុងស្រុកដូចគ្នាតែយើងត្រូវជ្រើសរើសពូជ ពីតំបន់ផ្សេង ដែលមាន់ទាំងពីរមិនមានជាប់ខ្សែស្រឡាយនឹងគ្នា ។

## ២.២-ការជ្រើសរើសពូជ

-ការជ្រើសរើសពូជនេះមានសារសំខាន់ណាស់ ដើម្បីឱ្យកាចិញ្ចឹមមាន់ទទួលបានលទ្ធផលល្អ
-គួរធ្វើការជ្រើសរើសមាន់ឱ្យសមស្របទៅតាមតំបន់ ឬ ពេលវេលារបស់យើង ហើយត្រូវគិតលើកត្តាតំលៃ កត្តាទីផ្សារ បទពិសោធន៏ និងការពេញនិយម ។

### ២.២.១-ការជ្រើសរើសស៊ុតមកភ្ញាស់

-ត្រូវយកស៊ុតពីមេពូជល្អ ដែលមានប្រវត្តិច្បាស់លាស់

-ស៊ុតត្រូវមានទំងន់ពី ៥0-៦0 ក្រាម (កន្លះខាំបន្ទិច)

- ស៊ុតត្រូវមានរាងសមស្រប ប្រវែងជុំវិញបណ្ដោយស្មើនឹង ១ ដ.ម ឬ ១ តឹក ហើយប្រវែងជុំវិញ ទទឹងស្មើនឹង ០,៧៥ ដ.ម ឬ ៧,៥ ធឹង
- ស៊ុតត្រូវម៉ត់រលីង មិនស្រាំ មិនវៀច មិនស្តើង មិនឆ្នូត ឬ អុច១ មិនប្រលាក់លាមក
- ហាមយកស៊ុតលាងទឹក

២.២.២-ការជ្រើសរើសមាន់ធំ

- ត្រូវយកមាន់ពីមេពូជល្អ ដែលមានប្រវត្តិច្បាស់លាស់
- សុខភាពមាំមួន មានសិរពណ៌ក្រហម ភ្នែកភ្លឺថ្លា រហ័សរហួន មិនកាចសាហាវ
- មាឌធំ លូតលាស់លឿន

-មាន់មេអាយុ ៤-៥ ខែ ផ្តល់ពង ១សារៗ យ៉ាងតិច ១០-១២ គ្រាប់
-មាន់ឈ្មោល ១ក្បាល អាចបង្កាត់ជាមួយមាន់មេ ពី ៨-១០ក្បាល
-ការប្រើប្រាស់មាន់មេ និងមាន់ឈ្មោលមិនឱ្យលើសបីឆ្នាំ

៣-ចំណើអាហារ និងទឹក

៣.១-ប្រភព និង ប្រភេទចំណីសំរាប់មាន់

-ចំណើផ្តល់ប្រូតេអ៊ីន(ជាតិសាច់)៖ មាននៅលើត្រី ម្សៅសាច់ ជន្លេន កណ្តូប កណ្តៀវ សណ្តែកសៀង កន្ទំថេត ។ល ។

-ចំណើផ្តល់ថាមពល(កំលាំង )៖ មាននៅលើស្រូវ អង្ករ ចុងអង្ករ ពោត កន្ទក់ ស្រូវសាឡី ។ល។

-ចំណើផ្តល់សារធាតុរ៉ែ(ជាតិឆ្អឹង)៖ មាននៅលើឆ្អឹង សំបកខ្យង សំបកលាស សំបកខ្ចៅ អំបិល ប្រេម៉ិច ។

-ចំណើផ្តល់វីតាមីន៖ មាននៅលើបន្លែបៃតង ស្លឹកស្មៅ ស្លែ ត្រកួន ផ្ទី កន្ទំថេត ។ល។

-ទឹកសំរាប់ផឹក៖ ផ្តល់ទឹកស្អាត និងគ្រប់គ្រាន់ដល់មាន់



៣.២-ការបង្កើតជន្លេន

-រៀបចំរណ្តៅជំរៅ ១ម បណ្តោយ ២ម និង ទទឹង ១ម មានក្រាលកៅស៊ូផង ការពារការវាចេញរបស់ជន្លេន ។ មានធ្វើតំបូល និង ដាក់របស់ការពារសត្វផ្សេងៗ

-ជ្រើសរើសរកមើលពូជជន្លេនដែលល្អ ជន្លេនថ្លូសៗ មានប្រវែង ១០-១៥ សង់ទីម៉ែត្រ ស្មើ ១-១,៥តឹក ។

-យើងអាចបង្កើតពូជជន្លេនបាន ដោយគ្រាន់តែដាក់អាចម៍គោ ក្របីស្រស់ គជាពំនូក (៣-៥បង្គី ) ដោយស្រោចទឹក ២ដងក្នុងថ្ងៃ ២-៣អាទិត្យក្រោយបានពូជ ឬរកពីកន្លែងផ្សេង ។

-ដាក់ជន្លេនចិញ្ចឹម ២-៣គីឡូក្រាម (៧០ ភាគរយ ជន្លេន និង ៣០ភាគរយ ជីលាមកសត្វជាប់ជន្លេន)

-ដាក់លាមកសត្វស្រស់ថ្មីៗ ១បង្គី (៥គីឡូក្រាម) ក្នុង ២ថ្ងៃម្តង

-ស្រោចទឹក ២ដងក្នុងមួយថ្ងៃ

-៤ខែ ប្រមូលផល បានពី២០-២៥គីឡូក្រាមក្នុង១ម៉ែត្រការ៉េ

**ករណីប្រើការមិនអស់**

-យកជន្លេន ៣ គ.ក្រ លាយកន្ទក់ ១គ.ក្រ រួមក្រឡុក ១០-១៥នាទី វាងាប់ រើសបំបែក ជន្លេន និងកន្ទក់ចេញពីគ្នា

-យកហាលថ្ងៃ ២-៣ថ្ងៃ ឱ្យស្ងួតល្អ

-ការផ្តល់ចំណី: អាចផ្តល់ឱ្យកូនមាន់ស៊ី ១-២ដង ក្នុង១អាទិត្យ បរិមាណ ១ខាំ ក្នុងមាន់ ១០ក្បាល ក្នុង១ដង ។

## ៣.៣- ការបង្កើតកណ្ដៀវ

**របៀបធ្វើ:**

-ជីករណ្ដៅជំរៅ 0,១៥ -0,២ ម ឱ្យបាន ១ ម៉ែត្រ បួនជ្រុង

-យកឈើងាប់ៗ តែយកផ្នែកខ្ចីៗ ដាក់តំរៀបក្នុងរណ្ដៅ

-យកសំបកបារចាស់ៗគ្របពីលើ

-ស្រោចទឹកទៅក្នុងរណ្ដៅរាល់ថ្ងៃ

-រក្សាទុករយៈពេល ៤-៥ ថ្ងៃ ទើបបើកសំបកបារ ឱ្យមាន់ស៊ីកណ្ដៀវ

-នៅពេលមាន់ស៊ីកណ្ដៀវអស់ ត្រូវរៀបចំសារជាថ្មី ប៉ុន្តែត្រូវរកឈើថ្មី

៣.៤-ទឹកសំរាប់ផឹក

-ត្រូវផ្តល់ទឹកស្អាត និងគ្រប់គ្រាន់ដល់មាន់ នៅក្នុងទឹកផឹកអាចលាយថ្នាំសំរាប់ការពារ ដូចជា:

-សង់តាអង់រ៉ូកូលី (GENTA ENROCOLI) មួយកញ្ចប់ លាយទឹក ១0លីត្រ ប្រើរយះពេល ២៤ម៉ោងឱ្យអស់ អាចប្រើម្តងទៀត ២-៣អាទិត្យម្តង

-ក្ល័របាក់ទ្រីម (CHLORBACTRIM ) មួយកញ្ចប់ លាយទឹក ៤0លីត្រ ប្រើរយះពេល ២៤ម៉ោងឱ្យអស់ អាចប្រើម្តងទៀត ២-៣អាទិត្យម្តង

ប្រសិនបើគ្មានថ្នាំខាងលើទេ អាចប្រើថ្នាំបុរាណ :

-សំរាប់នៅរដូវវស្សា: យកមើមខ្ទឹមស គល់ស្លឹកគ្រៃ រំដេង បុកលាយជាមួយគ្នាដាក់ត្រាំឱ្យមាន់ផឹក ប៉ុន្តែត្រូវផ្លាស់ប្តូរទឹករាល់ថ្ងៃ។

-សំរាប់នៅរដូវក្តៅ : យកសំបកគ សំបកស្តៅ វល្លិ៍បណ្តូលពេជ្រ បុកបញ្ចូលគ្នា ដាក់ត្រាំឱ្យមាន់ផឹកតែម្តង ប៉ុន្តែប្រយ័ត្នរវឹងជ្រុលបណ្តាលឱ្យមាន់មិនផឹក ។

-សំរាប់គ្រប់រដូវ : មើមសាគូ បុកលាយជាមួយដើមប្រមោយដំរី ដាក់ត្រាំទឹក ឱ្យមាន់ផឹក។

## ៤-ការថែទាំ និងវិធានការការពារ

### ៤.១-ការថែទាំ

#### ៤.១.១-ការថែទាំកូនមាន់

-យកកូនមាន់ដាក់ទ្រុង សំរាប់ចិញ្ចឹមកូនមាន់

-ត្រូវមានកំរាល ដូចជាសំបកឡាំងចាស់ៗ ឬ អាចប្រើអង្កាម ឬអាចម៍រណា ដាក់សំបកបារពីលើ

-ត្រូវមានស្នូកទឹក ស្នូកចំណី

-មួយថ្ងៃក្រោយភ្ញាស់ មិនបាច់ផ្តល់ចំណីឱ្យកូនមាន់ទេ

-ចំណីសំរាប់កូនមាន់ ត្រូវផ្តល់ចំណីណាដែលទន់ៗ ងាយស្រួលក្នុងការរំលាយ

-ត្រូវផ្តល់ចំណី និងទឹកគ្រប់គ្រាន់ប្រកបដោយគុណភាពដល់កូនមាន់

-ជ្រើសរើសកាន់កូនមាន់លេង
-ត្រូវធ្វើការចាក់ថ្នាំការពារជំងឺដល់កូនមាន់
-ត្រូវធ្វើការទំលាក់ព្រូនដល់កូនមាន់អាយុ ១,៥-២ខែ





## ៤.១.២-ការថែទាំមាន់ពេញវ័យ

-ត្រូវចិញ្ចឹមមាន់ក្នុងទ្រុងពាក់កណ្តាលលែង និងពាក់កណ្តាលបង្ខាំង

-ត្រូវមានទ្រនើរ ឬ បង្គងសំរាប់មាន់ដេកពេលយប់

-ត្រូវផ្តល់ចំណីឱ្យបាន ២ដងយ៉ាងតិច ក្នុង ១ថ្ងៃ

-ត្រូវផ្តល់ចំណី និងទឹកគ្រប់គ្រាន់ប្រកបដោយគុណភាព

-ត្រូវតាមដានត្រួតពិនិត្យមាន់រាល់ថ្ងៃពេលព្រឹក និង ល្ងាច

-ត្រូវមានសំបុកសំរាប់មាន់ពង

-ត្រូវមានរបាំងការពារពន្លឺ ភ្លៀង ខ្យល់

-ត្រូវបង្កាត់មាន់ឈ្មោល ១ក្បាល សំរាប់មាន់មេ ពី ៨-១០ ក្បាល

-ត្រូវចាក់ថ្នាំការពារជំងឺដល់មាន់

-ត្រូវទំលាក់ព្រូនដល់មាន់ រៀងរាល់ ៣ខែម្តង

-ត្រូវផ្លាស់ប្តូរមាន់រៀងរាល់ ៣ឆ្នាំម្តង

## ៤.២-វិធានការការពារ

### ៤.២.១-វិធានការអនាម័យ

-ត្រូវកើបលាមកមាន់រាល់ថ្ងៃ

-ត្រូវសំរាតស្នូកទឹក ស្នូកចំណើឱ្យបាន១-២ដងក្នុង១ថ្ងៃ

-ធ្វើសំរាតទីធ្លាជុំវិញជំរកដូចជាស្មៅ គម្ពោតព្រៃ កំទេចកំទី ។ល ។

-ធ្វើការសំលាប់មេរោគនៅជំរកមាន់ បរិវេណធ្លាសំរាប់មាន់ដើរ ដោយប្រើថ្នាំសំលាប់មេរោគ : ធីអេចហ្វ័រ (TH4) វីរាក់គីល (VIRAKIL) ហ្វីសស្តប់ (FIRSTOP) កំបោររស់ឱ្យបាន២ដងក្នុង១ឆ្នាំយ៉ាងតិច ។

-ត្រូវផ្តល់ចំណី និងទឹកគ្រប់គ្រាន់ប្រកបដោយគុណភាព

ករណីមាន់ឈឺ:

-ត្រូវបំបែកមាន់ជាចេញពីមាន់ឈឺ

-មាន់ឈឺត្រូវធ្វើការព្យាបាល

-មាន់ជាធ្វើការអង្កេតតាមដានឱ្យបាន ១០-១៥ថ្ងៃសិន

-ហាមវះសាកសពមាន់ស្លាប់ដោយជំងឺផ្តាសាយបក្សី (ជំងឺផ្លូង)

-មាន់ងាប់ត្រូវកប់ចោលក្នុងរណ្តៅ ឬដុតចោល

-ធ្វើការដុតកំទេចកំទីដែលនៅជាមួយមាន់ឈឺ ឬធ្វើការរំងាប់មេរោគ

-ហាមដឹកនាំមាន់ចេញចូលតំបន់មានជំងឺផ្លូង



ការសំលាប់មេរោគ ដោយបាញ់ល្បាយទឹក-កំបោរ ឬទឹក-ផេះ នៅកន្លែងមាន់ដេក ស៊ី និងសំរាក

## ៤.២.២-ការការពារ

**កម្មវិធីចាក់ថ្នាំការពារដល់មាន់ :**

-កូនមាន់អាយុ៧ថ្ងៃ ចាក់ថ្នាំការពារជំងឺញូវកាស ប្រភេទអាយធូបន្តក់ភ្នែក ច្រមុះ (អាចប្រើលើមាន់គ្រប់វ័យ)

-កូនមាន់អាយុ ១០ថ្ងៃ ចាក់ថ្នាំការពារជំងឺអុត ជួសលើស្លាបរង

-កូនមាន់អាយុ ១៤ថ្ងៃ ចាក់ថ្នាំការពារជំងឺរលាកទងសួត បន្តក់ភ្នែក ច្រមុះ

-មាន់អាយុ ២ខែកន្លះ ចាក់ថ្នាំការពារជំងឺអាសន្នរោគ ទីតាំងចាក់សាច់ដុំទ្រូង

ចំណាំ ករណីមាន់មិនដែលប្រើថ្នាំការពារសោះ ត្រូវធ្វើការចាក់រំលឹកឡើងវិញនៅ ៣-៤អាទិត្យក្រោយ ។


VA VISETH
MD

### ៤.២.៣-ការទំលាក់ព្រូន

**កម្មវិធីទំលាក់ព្រូនលើមាន់ :**

-កូនមាន់អាយុ ១,៥-២ខែ ធ្វើការទំលាក់ព្រូនលើកទី ១

-រយះពេល៣-៤អាទិត្យក្រោយ ធ្វើការទំលាក់ព្រូនម្តងទៀត លើកទី ២

-ការទំលាក់ព្រូនលើកទី ៣ បន្ទាប់ពីលើកទី ២ បីខែ ឬ ១ឆ្នាំទំលាក់ ៤ដង ។

(ចប់)


(FOWL CHOLERA)


ជម្ងឺញូកាស
(NEWCASTLE)

# សូមអរគុណ